**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមប្រឹក្សា
កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
អង្គភាពគ្រប់គ្រងគម្រោង
លេខ:០០៨/០៩ របក.អគគ

# របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ មីនា ឆ្នាំ ២០០៩ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ មីនា ឆ្នាំ ២០០៩ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោង ជាអង្គភាពប្រតិបត្តិ បានដំណើរការងារ របស់ខ្លួនស្របតាមបេសកកម្ម ដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

## ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌

### ក. ការងាររដ្ឋបាល

-ផ្ញើលិខិតជូនឯកឧត្តមអគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ស្តីពីបញ្ជីឈ្មោះសមាជិកចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ នាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ នៅ សណ្ឋាគារសាន់វ៉េ។

-ផ្ញើលិខិតស្នើសុំលិខិតបេសកកម្ម និងប័ណ្ណដើរផ្លូវសម្រាប់នាយក ប្រធានក្រុមគម្រោង និងអនុប្រធាន ក្រុមគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីចុះហត្ថលេខាលើអនុស្សារណៈយោគយល់ គ្នានៃការអនុវត្តគម្រោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ដំណាក់កាលទី៣ នៅខេត្តកំពង់ធំ និងខេត្តបន្ទាយមានជ័យ ចាប់ពីថ្ងៃទី០៩-១២ ខែមីនា ឆ្នាំ២០០៩។

-ផ្ញើលិខិតស្នើសុំអនុញ្ញាតិជាគោលការណ៍ ដើម្បីរៀបចំសន្និសីទស្តីពីឯករាជ្យភាពស្ថាប័ន និងសូមគោរពអញ្ជើញ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ចូលរួមជាអធិបតីក្នុងកម្មវិធីបើកអង្គសន្និសីទ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង ៨:៣០នាទី នៅសណ្ឋាគារកាំបូឌីយ៉ាណា។

-ផ្ញើលិខិតស្នើសុំអនុញ្ញាតិជាគោលការណ៍ពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីអញ្ជើញប្រធានតុលាការ និងព្រះរាជអាជ្ញាទូទាំងខេត្ត-ក្រុង មកចូលរួមសន្និសីទស្តីពីឯករាជ្យភាពស្ថាប័ន ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៦-២៧ ខែមីនា ឆ្នាំ២០០៩។

-ផ្ញើលិខិតអញ្ជើញអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ ចូលរួមធ្វើផែន ការសកម្មភាពតុលាការគំរូ នៅសាលាដំបូងខេត្តបន្ទាយមានជ័យ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ សាលាដំបូង រាជធានីភ្នំពេញ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩

សាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៩ សាលា ដំបូងខេត្តកំពង់ចាម នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ និងសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩។

-ផ្ញើលិខិតស្នើសុំឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចាត់តាំងរដ្ឋលេខាធិការក្រសួងមហាផ្ទៃមួយរូប ដើម្បីបញ្ចូលជាសមាជិកក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

-ផ្ញើលិខិតស្នើសុំលិខិតបេសកកម្ម និងប័ណ្ណដើរផ្លូវសម្រាប់នាយក ប្រធានក្រុមគម្រោង និងអនុប្រធាន ក្រុមគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីចុះទៅធ្វើផែនការសកម្មភាពតុលាការគំរូ នៅខេត្តកំពង់ចាម នៅថ្ងៃទី២៥-២៨ ខែមីនា ឆ្នាំ២០០៩។

-ទទួលលិខិតអញ្ជើញពី ប្រធានរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើក ទី៩ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាភិបាលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ នៅ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៩។

## ខ. ការងារកំណែទម្រង់

-បានរៀបចំឯកសារសម្រាប់ធ្វើបទបង្ហាញ ស្តីពីភាពជឿនលឿននៃការអនុវត្តកម្មវិធីសកម្មភាពសម្រាប់ អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅពេលប្រជុំពិគ្រោះយោបល់ទ្វេភាគីថ្នាក់ជាន់ខ្ពស់រវាងរដ្ឋា ភិបាលកម្ពុជា និងប្រទេសដាណឺម៉ាក នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ និងរវាងកម្ពុជា និងចក្រភពអង់គ្លេស នៅថ្ងៃ ទី១៩ ខែមីនា ឆ្នាំ២០០៩។

-បានជួបជាមួយលោកស្រី Maria Rasmussen មកពី DIHR (Danish Institute for Human Right) ដើម្បីពិភាក្សាពីបញ្ហាកិច្ចសន្ទនារវាងរដ្ឋ និងសង្គមស៊ីវិល។

-បានចូលរួមធ្វើផែនការសកម្មភាពតុលាការគំរូ នៅតាមបណ្តាខេត្តមួយចំនួន ដូចជា: សាលាដំបូងខេត្ត បន្ទាយមានជ័យ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩, សាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩, សាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៩, សាលាដំបូងខេត្តកំពង់ចាម នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ និងសាលាដំបូង រាជធានីភ្នំពេញ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៩។

-បានរៀបចំសិក្ខាសាលាស្តីពីការសិក្សាបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា នៅថ្ងៃសុក្រ ទី៦ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង ៨ព្រឹក នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់។

## គ. ផ្សេងៗ

-ចូលរួមកិច្ចប្រជុំអន្តរក្រសួង ពិភាក្សា និងប្រមូលផ្តុំមតិក្នុងការរៀបចំចងក្រង សេចក្តីព្រាងផែនការ សកម្មភាពអភិបាលកិច្ចទី៣ (២០០៩-២០១៣) នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៩។

-ចូលរួមអង្គប្រជុំអន្តរក្រសួង ពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វា កំពង់ផែសមុទ្រ នៅថ្ងៃ ទី២៦ ខែមីនា ឆ្នាំ២០០៩ នៅទីស្តីការគណៈរដ្ឋមន្ត្រី។

## ២-សន្និដ្ឋាន

ក្នុងខែ មីនា ឆ្នាំ ២០០៩ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានរៀបចំសិក្ខាសាលាស្តីពីការសិក្សាបញ្ចូលប្រព័ន្ធអំប៊ុដស្មាន់នៅកម្ពុជា នៅ ថ្ងៃសុក្រ ទី៦ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង ៨ព្រឹក នៅសណ្ឋាគារអាំងទែរកុងទីណង់តាល់ ដោយមានការចូលរួម ពីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធមួយចំនួន។

## ៣-ទិសដៅអនុវត្តក្នុងខែបន្ត

-បន្តអនុវត្តគម្រោងតុលាការគំរូ

-បន្តអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-បន្តអនុវត្តគម្រោងប្រព័ន្ធទិន្នន័យស្តីពីការលើកកំពស់សិទ្ធិនៅតាមមូលដ្ឋាន

-បន្តអនុវត្តគម្រោងកិច្ចសហប្រតិបត្តិការជាមួយ GTZ

-ត្រៀមរៀបចំសន្និសីទជាតិស្តីពីលទ្ធផលការងារសំខាន់ៗពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨

-ត្រៀមឯកសារ និងលិខិតអញ្ជើញសម្រាប់ប្រជុំក្រុមការងារបច្ចេកទេសចម្រុះ នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩។

រាជធានី ភ្នំពេញ ថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩

**អ្នកធ្វើរបាយការណ៍**

**ហ៊្វឹង សុកុល**

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

**ស៊ុយ ម៉ុងលាង**